រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០០១

# សេចក្តីសំរេច

## សេចក្តីសំរេចលេខ ១៥ សសរ

## ស្តីពីការបង្កើតក្រុមអ្នកចរចាសំរាប់ការចូលជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-បានឃើញសេចក្តីសំរេចលេខ ៣០ សសរ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់រាជ-រដ្ឋាភិបាលកម្ពុជា ស្តីពីការតែងតាំង និងដំណើរ ប្រព្រឹត្តទៅនៃគណៈកម្មាធិការសំរបសំរួល ការងារជាមួយអង្គការពាណិជ្ជកម្មពិភពលោក

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សំរេច

**ប្រការ ១ :** បង្កើតក្រុមអ្នកចរចាអន្តរក្រសួង សំរាប់ធ្វើការចរចាជាមួយសមាជិកនានា របស់អង្គការពាណិជ្ជកម្មពិភពលោក ដើម្បីធ្វើសមាហរណកម្មកម្ពុជាទៅជាសមាជិកពេញសិទ្ធិ របស់អង្គការពាណិជ្ជកម្មពិភពលោកដែលហៅកាត់ថា WTO។ ក្រុមអ្នកចរចានេះមានសមាសភាព ដូចខាងក្រោម :

១-ឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធាន

www.pheakdeylaw.com

២-ឯកឧត្តម **សុក ស៊ីផាន់ណា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម អនុប្រធាន

៣-ឯកឧត្តម **អ៊ុង គីមអន** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

**ក្រសួងពាណិជ្ជកម្ម**

៤-ឯកឧត្តម **ម៉ៅ ថូរ៉ា** អគ្គនាយកបច្ចេកទេស សមាជិក

៥-ឯកឧត្តម **ពេជ ឫទ្ធី** អគ្គនាយករងបច្ចេកទេស សមាជិក

៦-ឯកឧត្តម **សុខ សុភ័ក្ត្រ** ប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ សមាជិក

៧-លោក **តឹករ៉េត សំរេច** អនុប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ សមាជិក

៨-លោក **ម៉ែន សុទិជាតិ** អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា សមាជិក

៩-លោក **គ្រៃ ស៊ុនហៀង** ជំនួយការឯកឧត្តមរដ្ឋមន្ត្រី សមាជិក

**ទីស្តីការគណៈរដ្ឋមន្ត្រី**

១០-បណ្ឌិត **ជា វ៉ាន់ដេត** ប្រធានការិយាល័យសេដ្ឋកិច្ច សមាជិក

**ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

១១-លោក **នុយ វី** អគ្គនាយករង អគ្គនាយកដ្ឋានអាស៊ាន សមាជិក

១២-លោកស្រី **នួត បញ្ញា** ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៣-លោក **កែវ រិទ្ធិសិដ្ឋ** អនុប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល សមាជិក

១៤-លោក **ណៃ ម៉េងអាង** អនុប្រធាននាយកដ្ឋានអង្គការអន្តរជាតិ សមាជិក

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

១៥-ឯកឧត្តម **គង់ វិបុល** រដ្ឋលេខាធិការ សមាជិក

១៦-ឯកឧត្តម **សូ វិចឆំរ** អនុរដ្ឋលេខាធិការ សមាជិក

www.pheakdeylaw.com

១៧-លោក **គីម សុភ:** ជំនួយការអគ្គលេខាធិការនិងជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី សមាជិក

១៨-លោក **អ៊ុយ សម្បត្តិ** ប្រធាននាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន សមាជិក

១៩-លោក **គុណ ញឹម** នាយករងទីចាត់ការគយ និងរដ្ឋាករ សមាជិក

២០-លោក **អ៊ី សីហា** អនុប្រធានទី ១ នាយកដ្ឋានពន្ធដារ សមាជិក

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

២១-ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការ សមាជិក

២២-ឯកឧត្តម **ឈៀង យ៉ាំណារ៉ា** អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

២៣-អ្នកស្រី **ដេង សុភាព** មន្ត្រីនាយកដ្ឋានសំរបសំរួលកិច្ចការអន្តរក្រសួងនៃគណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

២៤-ឯកឧត្តម **គ្រី សារ៉ុន** អគ្គនាយក សមាជិក

២៥-លោក **ឡុត សារ៉ាវុធ** អនុប្រធាននាយកដ្ឋានផែនការស្ថិតិនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

២៦-លោក **ម៉ែន វុធ** អនុប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអរដីកសិកម្ម សមាជិក

២៧-លោក **សេន សុវណ្ណ** អនុប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល សមាជិក

**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

២៨-ឯកឧត្តម **ហ៊ុល លឹម** អនុរដ្ឋលេខាធិការ សមាជិក

២៩-លោក **ពីង ស៊ីវឡាយ** អនុប្រធាននាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម សមាជិក

៣០-លោក **ខ៊ិត ទីបុល** អនុប្រធានការិយាល័យកម្មសិទ្ធិឧស្សាហកម្ម សមាជិក

www.pheakdeylaw.com

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

៣១-ឯកឧត្តម **ឡុង វ៉ាន់ហាន** អនុរដ្ឋលេខាធិការ សមាជិក

៣២-កញ្ញា **ឡៅ ម៉ាយគៀង** អនុប្រធាននាយកដ្ឋានផែនការ គណនេយ្យ ហិរញ្ញវត្ថុ សមាជិក

**ក្រសួងផែនការ**

៣៣-ឯកឧត្តម **សារ៉ាក់ ខាន់** អនុរដ្ឋលេខាធិការ សមាជិក

៣៤-លោក **សួន សុខឃីម** អនុប្រធាននាយកដ្ឋាន សមាជិក

៣៥-លោក **ហួយ សិទ្ធិគុណ** អនុប្រធាននាយកដ្ឋាន សមាជិក

**ក្រសួងទេសចរណ៍**

៣៦-ឯកឧត្តម **សូ ម៉ារ៉ា** អគ្គនាយក សមាជិក

៣៧-លោក **អ៊ិន ចឿន** ប្រធាននាយកដ្ឋាន សមាជិក

**ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់**

៣៨-លោក **ហ៊ុយ ណារ៉ា** អគ្គនាយករង សមាជិក

៣៩-លោក **សោ វណ្ណា** អនុប្រធាននាយកដ្ឋាន សមាជិក

**ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច**

៤០-ឯកឧត្តម **ជា គង់** អគ្គនាយក សមាជិក

៤១-លោក **កែវ ធល្លា** ប្រធាននាយកដ្ឋាននីតិកម្ម សមាជិក

**ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

៤២-លោក **កែវ បូរ៉ែន្ទ** អគ្គនាយករង សមាជិក

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

៤៣-លោក **ជាម សុវណ្ណនី** អនុប្រធាននាយកដ្ឋានផែនការ សមាជិក

**ធនាគារជាតិនៃកម្ពុជា**

៤៤-លោកជំទាវ **តាល់ ណៃអ៊ីម** អគ្គនាយក សមាជិក

៤៥-លោកស្រី **ខ្វន សុខា** អនុប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច សមាជិក

**ក្រសួងសុខាភិបាល**

៤៦-លោកឱសថបណ្ឌិត **ច្រឹង សុខន** អនុប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខាពេទ្យ និងគ្រឿងសំអាង សមាជិក

**ក្រសួងយុត្តិធម៌**

៤៧-លោក **ផូច សំគី** ឧបការីឯកឧត្តមរដ្ឋមន្ត្រី សមាជិក

**សមាគមគណៈមេធាវី**

៤៨-លោក **ហែម ហ្វូណារិទ្ធ** មេធាវី សមាជិក

៤៩-លោក **នូ តេពីរិទ្ធ** ប្រធាននាយកដ្ឋានជំនួយផ្នែកច្បាប់ សមាជិក

**ប្រការ ២** : ក្រុមអ្នកចរចានេះមានភារកិច្ចដូចតទៅ :

ក-ធ្វើការចរចាជាមួយសមាជិកទាំងឡាយរបស់អង្គការពាណិជ្ជកម្មពិភពលោក លើរាល់ទិដ្ឋភាពនានានៃកិច្ចព្រមព្រៀងរបស់អង្គការនេះ ដែលទាក់ទងនឹងវិស័យ សេដ្ឋកិច្ច ច្បាប់ គោលនយោបាយទាក់ទង នឹងការធ្វើពាណិជ្ជកម្មលើទំនិញ និងសេវាកម្ម កសិកម្ម ឧស្សាហកម្ម វិនិយោគ កម្មសិទ្ធិបញ្ញា និងផ្នែកពាក់ព័ន្ធ ផ្សេងៗទៀត ដែលនឹងប្រព្រឹត្តិទៅចាប់ពីខែឧសភា ឆ្នាំ ២០០១ នេះតទៅ ។

ខ-រៀបចំចងក្រងឯកសារច្បាប់ បទប្បញ្ញត្តិនានា របស់ក្រសួងពាក់ព័ន្ធ និងឯកសារគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សមាជិកនានា និងសំរាប់ធ្វើជា មូលដ្ឋានបង្អែកក្នុងការចរចា ។

www.pheakdeylaw.com

គ-រាយការណ៍ និងលើកសំណើ ជូនរាជរដ្ឋាភិបាលក្នុងការកសាងផែនការសកម្មភាព សំរាប់ ប្រទេសកម្ពុជាក្នុងការត្រៀម អនុវត្តកិច្ចព្រមព្រៀងនានារបស់អង្គការពាណិជ្ជកម្មពិភពលោក ក្នុងដំណាក់កាលចរចា និងនៅពេលដែលកម្ពុជាក្លាយជាសមាជិកពេញសិទ្ធិ ។

**ប្រការ ៣** : ក្រុមអ្នកចរចាត្រូវមានខ្ទង់ថវិកាដោយឡែកមួយ ដែលជាឧបសម្ព័ន្ធនៃថវិកាប្រចាំឆ្នាំរបស់ក្រសួងពាណិជ្ជកម្មសំរាប់ប្រើប្រាស់ក្នុងការចរចា និងក្នុងសកម្មភាពនានាដែលពាក់ព័ន្ធនឹងការចរចា ។ នៅពេលដែលខ្ទង់ថវិកានេះមិនទាន់បានលើគំរោងបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ក្រសួងពាណិជ្ជកម្ម ក្រុមអ្នកចរចា អាចប្រើប្រាស់ថវិកាបុរេប្រទានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាន ។ ប្រធានក្រុម អ្នកចរចាមានសិទ្ធិប្រើប្រាស់ថវិកានេះ ទៅតាមការចាំបាច់ជាក់ស្តែង ។

**ប្រការ ៤** : ប្រធានក្រុមអ្នកចរចាមានសិទ្ធិសំរេចក្នុងការផ្លាស់ប្តូរ ឬជ្រើសរើសចំរាញ់យកសមាជិករបស់ខ្លួនដើម្បីទៅចូលរួមក្នុងវគ្គចរចានីមួយៗ ។ ក្នុងករណីចាំបាច់ ប្រធានក្រុមអ្នកចរចា មានសិទ្ធិស្នើសុំយកមន្ត្រីជាន់ខ្ពស់របស់ក្រសួងស្ថាប័នពាក់ព័ន្ធដទៃទៀត បញ្ចូលទៅក្នុងក្រុមអ្នកចរចា ។

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ទេសាភិបាលធនាគារ នៃជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ប្រធានគណៈមេធាវីកម្ពុជា និងរដ្ឋមន្ត្រី ព្រមទាំងប្រធាន ស្ថាប័នពាក់ព័ន្ធដទៃ

www.pheakdeylaw.com

ទៀត ត្រូវអនុវត្តតាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ថ្ងៃទី ៣០ ខែ មិនា ឆ្នាំ ២០០១

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ចម ប្រសិទ្ធ**

---

រាជធានីភ្នំពេញ ថ្ងៃ ទី ០៣ ខែ មេសា ឆ្នាំ ២០០១

## សេចក្តីសំរេចលេខ១៦ សសរ

## ស្តីពី

## ការបង្កើតគណកម្មាធិការជាតិ គ្រប់គ្រងជីវៈចំរុះ

~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ

www.pheakdeylaw.com
~~~